THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
Superintendent

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ថ្ងៃរៀនចុងក្រោយនៅតែប៉ុន្មានថ្ងៃទៀត ហើយរដូវក្តៅក៏ខិតជិតមកដល់។ នៅពេលដែលយើងបញ្ចប់ឆ្នាំសិក្សានេះ ខ្ញុំសូមជំរុញសិស្សានុសិស្ស និងក្រុមគ្រួសារឱ្យបញ្ចប់ការសិក្សាឱ្យបានខ្លាំង! សិស្សគួរតែមករៀនជារៀងរាល់ថ្ងៃក្នុងសប្តាហ៍នេះ ហើយឆ្ពោះទៅកាន់រដូវក្តៅដោយមោទនភាព ដើម្បីរីករាយនឹងសកម្មភាពសប្បាយៗ និងពេលវេលាដ៏មានតម្លៃជាមួយក្រុមគ្រួសារ និងមិត្តភក្តិ។ ខាងក្រោមនេះគឺជាព័ត៌មានមួយចំនួនដើម្បីជួយយើងទាំងអស់គ្នាឱ្យសប្បាយរីករាយក្នុងរដូវក្តៅយ៉ាងពេញទំហឹង និងត្រៀមខ្លួនយើងសម្រាប់ឆ្នាំសិក្សា 2024-25 ដែលប្រកបដោយជោគជ័យ។

**ការសិក្សាក្នុងរដូវក្តៅ**

កម្មវិធីសិក្សាក្នុងរដូវក្តៅ ចាប់ផ្តើមនៅថ្ងៃទី **25** ខែ មិថុនា ឆ្នាំ **2024** សម្រាប់សិស្សដែលបានចុះឈ្មោះរៀននៅក្រសួងអប់រំ។ នៅមានកន្លែងក្នុង កម្មវិធីសហគ្រិនយុវវ័យ (Young Entrepreneurs Program) របស់យើងសម្រាប់សិស្សដែលនឹងចូលរៀនថ្នាក់ទី **9** ។ ស្វែងយល់បន្ថែម និងចុះឈ្មោះសម្រាប់សហគ្រិនយុវវ័យ នៅទីនេះ។ លើសពីនេះ នៅមានកន្លែងមួយចំនួននៅទីតាំងនៃកម្មវិធី Summer Achievers របស់យើង សម្រាប់សិស្សដែលនឹងចូលរៀនថ្នាក់ទី 1 ដល់ទី 8 ។ លោកអ្នកអាចចូលទៅកាន់ គេហទំព័រនៃកម្មវិធីក្នុងរដូវក្តៅ Summer Programs website ដើម្បីស្វែងយល់បន្ថែម ឬចូលទៅកាន់បញ្ជីសម្រាប់ទីតាំងនៃកម្មវិធី Summer Achievers នៅទីនេះ។

មិនថាក្មេងចូលរួមក្នុងកម្មវិធីនៅរដូវក្តៅឬអត់ យើងជំរុញឪពុកម្តាយ និងក្រុមគ្រួសារឱ្យគាំទ្រដល់ការបន្តការសិក្សានៅផ្ទះ។ សូមទៅកាន់បណ្ណាល័យក្នុងតំបន់ ដើម្បីខ្ចីសៀវភៅមួយចំនួនដែលមាននៅក្នុង បញ្ជីសម្រាប់អានក្នុងរដូវក្តៅ summer reading list របស់យើង។ លើសពីនេះ ឯកសារនៃការណែនាំសម្រាប់គណិតវិទ្យាក្នុងរដូវក្តៅនេះ this document of Summer Math Recommendations ផ្តល់ជាគំនិតដើម្បីជួយសិស្សនៅគ្រប់កម្រិតថ្នាក់ប្រើនូវជំនាញផ្នែក លេខ រាង ទិន្នន័យ និងលំនាំ ក្នុងពិភពលោកដែលនៅជុំវិញពួកគេ។ ទីក្រុង ហ្វីឡាដែលហ្វ្យ៉ា ក៏ផ្តល់សកម្មភាព និងកម្មវិធីផ្សេងៗ ដែលមានតម្លៃទាប និងឥតគិតថ្លៃ សម្រាប់ក្មេង និងយុវវ័យក្នុងរដូវក្តៅផងដែរ។ សូមចូលទៅកាន់គេហទំព័រ www.phila.gov/families សម្រាប់ទីតាំង និងព័ត៌មានបន្ថែម។

**រក្សាទំនាក់ទំនងតាមរយៈអនឡាញ**

ក្រសួងអប់រំនឹងខិតខំប្រឹងប្រែងធ្វើការក្នុងរដូវក្តៅនេះ ដើម្បីត្រៀមសម្រាប់ឆ្នាំសិក្សាក្រោយ។ នោះមានន័យថាយើងនឹងចែករំលែកព័ត៌មាន និងព័ត៌មានថ្មីៗជាមួយលោកអ្នកក្នុងរដូវក្តៅនេះ ជាពិសេសនៅពេលដែលយើងខិតជិតដល់ថ្ងៃចូលរៀនដំបូង។ អ៊ិនធ័រណិតដែលអាចទុកចិត្តបាននឹងមានសារៈសំខាន់ក្នុងការទទួលបានព័ត៌មាន

ថ្មីៗ។ ទោះបីជា កម្មវិធីតភ្ជាប់អ៊ិនធឺណិតដែលមានតម្លៃសមរម្យ (ACP) របស់ទីក្រុង ហ្វីឡាដែលហ្វ្យា បានចប់ក៏ដោយ ទីក្រុងគាំទ្រក្រុមគ្រួសារក្នុងការទទួលបានអ៊ិនធឺណិតដោយឥតគិតថ្លៃ ឬតម្លៃទាប តាមរយៈនេះកម្មវិធី PHLConnectED ។ ប្រសិនបើលោកអ្នកបានកត់សម្គាល់ថា សេវាកម្មរបស់លោកអ្នកបានបញ្ចប់ ឬវិក្កយបត្ររបស់លោកអ្នកកើនតម្លៃ ឬប្រសិនបើលោកអ្នកគ្រាន់តែស្វែងរកជម្រើសអ៊ិនធឺណិតដែលមានតម្លៃទាប សូមចូលទៅកាន់គេហទំព័រ PHLConnectED website ឬចុចលេខ 2-1-1 ដើម្បីនិយាយជាមួយអ្នកផ្តល់ជំនួយដល់អ្នកដែលត្រូវការអ៊ិនធឺណិតដែលមានតម្លៃទាបរបស់ទីក្រុង ហ្វីឡាដែលហ្វ្យា។

**ការចាក់ថ្នាំបង្ការរោគ និងពិនិត្យរាងកាយ**

ក្រសួងអប់រំបានរួមគ្នាជាមួយ Delaware Valley Community Health, Black Doctors Consortium និង The Family Practice & Counseling Network ដើម្បីផ្តល់ថ្នាំបង្ការរោគ និងការពិនិត្យរាងកាយសម្រាប់កីឡាដល់សិស្សរបស់ក្រសួងអប់រំ នៅទីតាំងមួយចំនួននៅខែ កក្កដា និង សីហា។ សេវាកម្មពិនិត្យរាងកាយសម្រាប់កីឡា និងចាក់ថ្នាំបង្ការរោគ ត្រូវបានផ្តល់ឱ្យសិស្សទាំងអស់ដោយមិនគិតពីស្ថានភាពធានារ៉ាប់រងឡើយ។ ដើម្បីស្វែងរកកាលបរិច្ឆេទ និងទីតាំងចាក់ថ្នាំបង្ការរោគនៅរដូវក្តៅ និងព្រឹត្តិការណ៍ពិនិត្យរាងកាយ សូមមើលតម្រូវការនៃឯកសារសម្រាប់អាយុ និងឯកសារសម្រាប់ព្រឹត្តិការណ៍អ្វីមួយ ហើយធ្វើការណាត់ជួបតាមរយៈគេហទំព័រ www.philasd.org/vax ។

សិស្សក៏អាចទទួលការពិនិត្យធ្មេញដោយឥតគិតថ្លៃក្នុងរដូវក្តៅ នៅមន្ទីរពេទ្យធ្មេញកុមារដែលស្ថិតនៅសាលា WD Kelley អាស័យដ្ឋាន 1601 N 28th St., Philadelphia, PA 19121។ មន្ទីរពេទ្យធ្មេញផ្តល់ការពិនិត្យធ្មេញ ការបំពេញធ្មេញប្រហោង ស្រោបធ្មេញ ដកធ្មេញ និងការព្យាបាលបន្ទាន់។ ស្វែងយល់ពីរបៀបធ្វើការណាត់ជួបដោយចូលទៅកាន់ គេហទំព័រសុខភាពសិស្ស Student Health website។

តាមពិត មានអ្វីៗជាច្រើនដែលត្រូវធ្វើនៅរដូវក្តៅនេះ ក្នុងការរៀបចំសម្រាប់ **ថ្ងៃច័ន្ទ ទី 26 ខែសីហា** – ដែលជាថ្ងៃចូលរៀនដំបូង។។ សូមព្យាយាមមើលព័ត៌មានបន្ថែមក្នុងរដូវក្តៅនេះ រួមទាំងព័ត៌មានអំពី រថយន្តសាលាដែលផ្សព្វផ្សាយពីការត្រឡប់មករៀនវិញប្រចាំឆ្នាំលើកទី 4 (4th Annual Back-to-School Bus Tour) របស់យើង ដើម្បីឱ្យលោកអ្នកត្រៀមខ្លួនបានយ៉ាងល្អក្នុងការវិលត្រឡប់មករៀនវិញនៅរដូវស្លឹកឈើជ្រុះ។ រហូតដល់ពេលនោះ សូមសប្បាយរីករាយក្នុងរដូវក្តៅនេះ!

ក្នុងភាពជាដៃគូ,

*Tony*

Tony B. Watlington Sr., Ed.D.
អគ្គនាយកនៃក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា